សាលាដំបូងខេត្តមណ្ឌលគិរី
-សំណុំរឿងព្រហ្មទណ្ឌលេខ២៥៩
ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨
-សំណុំរឿងជំនុំជម្រះលេខ២៣៧
ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១
-សាលក្រមលេខ ៨២
ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០២២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តមណ្ឌលគិរី

បានបើកសវនាការជាសាធារណៈនាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ ដែលមានសមាសភាពជំនុំជម្រះដូចតទៅ:

### ចៅក្រមជំនុំជម្រះ

ឯកឧត្តម [redacted] ចៅក្រមជំនុំជម្រះ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តមណ្ឌលគិរី

### ក្រឡាបញ្ជីសវនាការ

លោក **លី ចន** ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តមណ្ឌលគិរី

### មេធាវី

លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យសហដើមបណ្តឹង ១.ឈ្មោះ[redacted] គាយ, ២.ឈ្មោះ [redacted] សុខិត, ៣. ឈ្មោះ[redacted]សុផាត, ៤.ឈ្មោះ[redacted] ញ្ញង, ៥.ឈ្មោះ[redacted] មឿន, ៦.ឈ្មោះ[redacted] គា, ៧.ឈ្មោះ [redacted] ញៀន, ៨.ឈ្មោះ[redacted] គ្រួល, ៩.ឈ្មោះ [redacted] សៅ និង ឈ្មោះ[redacted] ឌីត។

លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ[redacted] សុរិយា ។

-ដើម្បីជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ: ២៥៩ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ[redacted]**សុរិយា** ភេទប្រុស អាយុ ៣៤ឆ្នាំ ជានីតិជន ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើតភូមិ[redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិអូរស្ពាន សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ឪពុកឈ្មោះ [redacted] ផាប់ (រ) ម្តាយឈ្មោះ [redacted] គីមឡេង (រ) នៅលីវ ប្រវត្តិផ្តន្ទាទោសពីមុន គ្មាន ។

ជាប់ចោទពីបទ: **ធ្វើឲ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:

កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧ និងនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៨ ឈ្មោះ [redacted] សូរិយា បានឈូសឆាយដីមួយកន្លែងដែលស្ថិតនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ដែលជាដីចំការវិលជុំ តាមលក្ខណៈប្រពៃណីរបស់ជនជាតិដើមភាគតិច បណ្តាលឱ្យខូចខាតដំណាំមួយចំនួនមានដូចជា៖ ដើមស្វាយ ចេក ខ្នុរ ម្នាស់ ប័រ កាហ្វេ និងផ្ទះចាំចំការចំនួន ០២ លើផ្ទៃដីប្រមាណ ១៤ ហិកតា ។

-បានឃើញ: ដីកាដំណោះស្រាយលេខ: ១៣២៣/២១ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តមណ្ឌលគិរី ។

-បានឃើញ: សំណុំរឿងព្រហ្មទណ្ឌជំនុំជម្រះលេខ: ២៣៧ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តមណ្ឌលគិរី ។

-បានឃើញ: ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ២៣៧ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តមណ្ឌលគិរី ។

-បានឃើញ: ដីកាសម្រេចដាក់ជំនុំជម្រះលេខ: ១៤០៥/២១ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តមណ្ឌលគិរី ។

## នាពេលសវនាការ

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] សូរិយា បានឆ្លើយថា៖ នៅឆ្នាំ២០១៧ ខ្លួនបានស៊ីឈ្នួលឈូសឆាយដីឱ្យឈ្មោះ ជា ពិតមែន ដោយឈ្មោះ ជា បានបង្ហាញឯកសារលក់-ទិញ ពីប្រជាពលរដ្ឋដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី របស់ឈ្មោះ [redacted] ចាន់លី ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៦, លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី របស់ឈ្មោះ [redacted] ស្រីថាន ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៦ និងគំនូសបង្ហាញទ្រង់ទ្រាយដីវាស់ដោយ GPS India Thai Lang60 ចុះហត្ថលេខាទទួលស្គាល់ឱ្យអាជ្ញាធរមានសមត្ថកិច្ចតាមលំដាប់ ដែលមានទីតាំងនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ទំហំប្រហែល ១០ហិកតា ដោយរាប់អានគ្នា ខ្លួនក៏យកថ្លៃឈ្នួល ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិច ។ ហើយដីនេះពុំមែនជាកម្មសិទ្ធិរបស់ខ្លួនទេ ។ បន្ទាប់មកខ្លួនក៏បានយកគ្រឿងចក្រចូលឈូសឆាយដី ទៅតាមការសន្យាគ្នាតាមចំណុចប្លង់កាន់កាប់ដីនោះ ខ្លួនឃើញមានដំណាំ ហើយម្ចាស់ដីក៏ប្រាប់ថាឱ្យឈូសសំអាតទាំងអស់ទៅ ខ្លួនជាអ្នកស៊ីឈ្នួល ខ្លួនក៏ឈូសតាមម្ចាស់គេតែម្តង។ មួយវិញទៀតខ្លួនដឹងដីនេះច្បាស់បានហ៊ានចូលឈូសឆាយ ព្រោះខ្លួនបានធ្វើជាសាក្សីក្នុងការទិញលក់ដីរបស់ឈ្មោះ [redacted] ចាន់លី និងឈ្មោះ [redacted] ស្រីថាន ។ ពេលខ្លួនឈូសឆាយដីបានប្រហែលមួយសប្តាហ៍ក្រោយមកស្រាប់តែមានប្រជាពលរដ្ឋជនជាតិព្នងមកហាមឃាត់ ហើយខ្លួនក៏បានបង្ហាញឯកសារម្ចាស់ដី និងបានផ្អាកការឈូសឆាយសិន និងបាននាំគ្នាទៅដោះស្រាយនៅសាលាឃុំដាក់ដាំ រឿងដំណាំ តែជនជាតិគាត់ទាមទារតែដី ដោយខ្លួនពុំមែនជាម្ចាស់ដីទេ។ ជាលទ្ធផលអាជ្ញាធរឃុំមិនអាចដោះស្រាយចេញ ដោយសារតែពលរដ្ឋជនជាតិព្នងទាំងនោះពុំមានឯកសារទេ ប៉ុន្តែម្ចាស់ដីបានប្រាប់មកខ្លួនថាឱ្យទុករយៈពេលមួយអាទិត្យដើម្បីឱ្យពួកជនជាតិដោះស្រាយ។ នៅឆ្នាំ២០១៨ ឈ្មោះ ជា បានជួលខ្លួនឱ្យទៅសម្អាតដីនោះម្តងទៀត ដើម្បីរៀបចំដីដាំដំណាំ ប៉ុន្តែត្រូវពលរដ្ឋជនជាតិព្នងមកហាមឃាត់ម្តង

ទៀត ហើយការហាមឃាត់នោះពួកគាត់មិនមានបង្ហាញឯកសារអ្វីដែរ។ ដោយសារខ្លាចមានអំពើហិង្សាកើតឡើង ទើបខ្លួនឱ្យកម្មករបញ្ឈប់សកម្មភាពសិន។ ក្រោយមកអាជ្ញាធរឃុំក៏បានហៅទៅដោះស្រាយ ប៉ុន្តែនៅតែគ្មានដំណោះស្រាយដដែល ដោយសារតែពលរដ្ឋទាំងនោះពុំមានឯកសារអ្វីសោះ ហើយទាមទារតែដីពីខ្លួន ខ្លួននិយាយរឿងដំណាំគាត់អត់ព្រម។ នៅពេលចូលឈូសឆាយនោះ ស្ថានភាពដីគឺមានព្រៃរបោះ ហើយការឈូសឆាយនោះ ដំបូងឡើយខ្លួនមិនបានដឹងថាមានការខូចខាតដំណាំទេ ប៉ុន្តែក្រោយពេលប្រជាពលរដ្ឋធ្វើការតវ៉ា ហើយខ្លួនចុះទៅដោះស្រាយទើបដឹងថា មានខូចខាតដំណាំតិចតួច មានដូចជាដើមប័រ ចំនួន ១០ដើម ម្នាស់ និងដំឡូងមី ដែលដុះនៅ លាយឡំជាមួយព្រៃរបោះ ហើយទំហំដែលដាំនោះប្រហែលជា ០១ហិកតាប៉ុណ្ណោះ ។ ខ្លួនពុំបានដឹងពីរឿងដីសហគមន៍នោះទេ សូម្បីតែមេឃុំក៏គាត់ពុំបានដឹងរឿងដីសហគមន៍ផង។

-ចម្លើយដើមបណ្តឹងឈ្មោះ [redacted] តាយ បានឆ្លើយថា៖ ដីដែលពួកខ្លួនបានកាន់កាប់ ពុំមានឯកសារបញ្ជាក់ទេ មានដំណាំជាក់ស្តែងលើដីដូចជា ដើមស្វាយ ដើមចេក ដើមប័រ ដើមខ្នុរ និងដំណាំផ្សេងៗជាច្រើនទៀត គឺដីនេះពួកខ្លួនបានទទួលបានពីដូនតាតាំងពីឆ្នាំ១៩៨៤ មកម្លេះ ។ រហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ ពួកខ្លួនទាំង ៧៧គ្រួសារ បានផ្តិតមេដៃប្រគល់សិទ្ធិឱ្យលោក [redacted] ធ្វើក ជាអ្នកតំណាងឱ្យក្រុមសហគមន៍ និងជាប្រធានគណៈកម្មាធិការសហគមន៍ជនជាតិភាគតិចព្នង នៃភូមិពូឆប បានធ្វើពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ជនជាតិភាគតិច ទៅលោកប្រធានមន្ទីររៀបចំដែនដី នគររូបនីយកម្មសំណង់ និងសុរិយោដី ខេត្តមណ្ឌលគិរី តាមរយៈលោកមេឃុំដាក់ដាំ ។ បន្ទាប់មកលោកមេឃុំដាក់ដាំក៏បានចេញលិខិតស្តីពីការតែងតាំងគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិចព្នងភូមិពូឆប ហើយក៏មានសេចក្តីសម្រេចស្តីពីការតែងតាំងគណៈកម្មាធិការសហគមន៍ជនជាតិភាគព្នង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥។ ក្រោយមកក្រសួងមហាផ្ទៃ ក៏បានជម្រាបមកលោក [redacted] ធ្វើក ប្រធានសហគមន៍ជនជាតិដើមភាគតិច ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦។ ហើយក្រសួងដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដី ខេត្តមណ្ឌលគិរី បានធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការកំណត់ព្រំវាស់វែង និងវិនិច្ឆ័យដីសហគមន៍ជនជាតិដើមភាគតិចព្នងពូឆប ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ព្រមទាំងមានប្លង់សុរិយោដី ផងដែរ ។ លុះដល់ឆ្នាំ២០១៧ ឈ្មោះ [redacted] សូវិយា បានយកគ្រឿងចក្រមកឈូសឆាយដីខាងលើប្រហែលជា ០១ហិកតា លើកទី១ ។ ក្រោយមកអំឡុងខែវិច្ឆិកា ឆ្នាំ២០១៨ ឈ្មោះ [redacted] សូវិយា ក៏បានយកគ្រឿងចក្រមកឈូសឆាយបន្តទៀតអស់ទំហំសរុបប្រហែល ១៤ហិកតា នៅលើដីសហគមន៍ជនជាតិភាគតិច ។ បន្ទាប់ពីឃើញសកម្មភាពឈូសឆាយបែបនេះ ពួកខ្លួនទាំង ១៤គ្រួសារបានទៅហាមឃាត់ឈ្មោះ [redacted] សូវិយា មិនឱ្យធ្វើការឈូសឆាយបន្ត ហើយឈ្មោះ [redacted] សូវិយា បានផ្អាកសកម្មភាពឈូសឆាយមួយរយៈ ប៉ុន្តែបានបន្តមកឈូសឆាយបានកាយរណ្តៅទទឹងប្រហែល ០៥ម៉ែត្រ បណ្តោយប្រហែល៧ ទៅ៨ម៉ែត្រ ដោយយកអាចម៍ដីកាយរណ្តៅនោះមកជះគប់លើដំណាំជាច្រើនមាន៖ ដើមប័រចំនួន ២០០ដើម,ដើមកូនកាហ្វេចំនួន ១០៥០ដើម,ដើមស្វាយចំនួន ១០០ដើម (មាន



Scanned with CamScanner

អាយុ៥ទៅ៦ឆ្នាំហើយ) ដើមខ្នុរចំនួន ១០០ដើម ដើមចេកចំនួន ១០គុម្ព ដើមដំឡូងមីប្រហែលជា ១.៥ហិកតា និងផ្ទះចំការចំនួន ០២ផងដែរ ។ រហូតដល់ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ប្រជាពលរដ្ឋទាំង ១៤គ្រួសារបាននាំគ្នាទៅសាលាឃុំ ដើម្បីឱ្យមេឃុំជួយដោះស្រាយ បន្ទាប់មកខាងអាជ្ញាធរឃុំក៏បានហៅភាគីឈ្មោះ [redacted] សូរិយា និងប្រជាពលរដ្ឋទាំង ១៤គ្រួសារមកតទល់ និងយកលិខិតកាន់កាប់ដីធ្លីមកផ្ទៀងផ្ទាត់គ្នា ។ ប៉ុន្តែក្រោយមកខាងអាជ្ញាធរឃុំ ពុំមានដំណោះស្រាយអ្វីមកឱ្យប្រជាពលរដ្ឋជនជាតិព្នងទាំង ១៤គ្រួសារឡើយ ។ ហើយពួកខ្លួនក៏បានបន្តដាក់ពាក្យបណ្តឹងទៅសាលាស្រុកអូររាំង និងសាលាខេត្តមណ្ឌលគិរី ប៉ុន្តែនៅតែមិនមានដំណោះស្រាយសមស្របណាមួយទេ។ រហូតដល់ពួកខ្លួនដាក់ពាក្យបណ្តឹងមកអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរីតែម្តង ។

- មេធាវីការពារសិទ្ធិឱ្យសហដើមបណ្តឹងថា ដីសហគមន៍បានស្នើសុំត្រឹមត្រូវរហូតទៅដល់ក្រសួងរៀបចំដែនដីរួចហើយ ប៉ុន្តែពុំមានសេចក្តីសម្រេចចុងក្រោយចេញមកទេ គឺកំពុងរង់ចាំ។

-ចម្លើយដើមបណ្តឹងឈ្មោះ [redacted] សុភាព បានឆ្លើយថា៖ ដីដែលពួកខ្លួនបានកាន់កាប់ មានដំណាំដូចជា ដើមស្វាយ ដើមចេក ដើមប័រ ដើមខ្នុរ និងដំណាំផ្សេងៗជាច្រើនទៀត គឺដីនេះពួកខ្លួនបានទទួលបានពីដូនតាតាំងពីឆ្នាំ១៩៨៤ (ខ្លួននៅតូច) មកម្លេះ ជាដីចំការវិលជុំរបស់ខ្លួនមានបីតំណមកហើយ(បីជំនាន់) មានជីដូន ឪពុកម្តាយ និងខ្លួនធ្វើបច្ចុប្បន្ននេះ ហើយខ្លួនបានចាកចេញពីដីនេះទៅរស់នៅកោះញែក ហើយនៅឆ្នាំ១៩៨២ ខ្លួនមកនៅភូមិពូឆបនេះ រហូតមានរឿងបែបនេះ ហើយមានផ្លូវកាត់ដីនេះមួយខ្សែ ដែលមានប្រជាជនដឹងឮ។ រហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ ពួកខ្លួនទាំង ៧៧គ្រួសារ បានផ្តិតមេដៃប្រគល់សិទ្ធិឱ្យលោក [redacted] ធ្វើក ជាអ្នកតំណាងឱ្យក្រុមសហគមន៍ និងជាប្រធានគណៈកម្មាធិការសហគមន៍ជនជាតិភាគតិចព្នង នៃភូមិពូឆប បានធ្វើពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ជនជាតិភាគតិច ទៅលោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដី ខេត្តមណ្ឌលគិរី តាមរយៈលោកមេឃុំដាក់ដាំ ។ បន្ទាប់មកលោកមេឃុំដាក់ដាំ ក៏បានចេញលិខិតស្តីពីការតែងតាំងគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិចព្នងភូមិពូឆប ហើយក៏មានសេចក្តីសម្រេចស្តីពីការតែងតាំងគណៈកម្មាធិការសហគមន៍ជនជាតិភាគព្នង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥។ ក្រោយមកក្រសួងមហាផ្ទៃ ក៏បានជម្រាបមកលោក [redacted] ធ្វើក ប្រធានសហគមន៍ជនជាតិដើមភាគតិច ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ។ ហើយក្រសួងដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី ខេត្តមណ្ឌលគិរី បានធ្វើរបាយការណ៍ស្តីពីលទ្ធផល នៃការកំណត់ព្រំរាស់វែង និងវិនិច្ឆ័យដីសហគមន៍ជនជាតិដើមភាគតិចព្នងពូឆប ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ព្រមទាំងមានប្លង់សុរិយោដី ផងដែរ ។ ស្រាប់តែនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៧ ឈ្មោះផេង សូរិយា បានយកគ្រឿងចក្រមកឈូសឆាយដីខាងលើប្រហែលជា ០១ហិកតា លើកទី១ ។ ក្រោយមកអំឡុងខែវិច្ឆិកា ឆ្នាំ២០១៨ ឈ្មោះ [redacted] សូរិយា ក៏បានយកគ្រឿងចក្រមកឈូសឆាយបន្តទៀតអស់ទំហំសរុបប្រហែល ១៤ហិកតា

នៅលើដីសហគមន៍ជនជាតិភាគតិច ។ បន្ទាប់ពីឃើញសកម្មភាពឈូសឆាយបែបនេះ ពួកខ្លួនទាំង ១៤គ្រួសារបានទៅហាមឃាត់ឈ្មោះ [redacted] សូរិយា មិនឲ្យធ្វើការឈូសឆាយបន្ត ហើយឈ្មោះ [redacted] សូរិយា បានផ្អាកសកម្មភាពឈូសឆាយ ប៉ុន្តែមកឈូសឆាយបន្ត បានកាយរណ្តៅទទឹងប្រហែល ០៥ម៉ែត្រ បណ្តោយប្រហែល៧ ទៅ៨ម៉ែត្រ ដោយយកអាចម៍ដីកាយរណ្តៅនោះមកជះកប់លើដំណាំជាច្រើនមាន៖ ដើមប័រចំនួន ២០០ដើម,ដើមកូនកាហ្វេចំនួន ១០៥០ដើម, ដើមស្វាយចំនួន ១០០ដើម (មានអាយុ៥ទៅ៦ឆ្នាំហើយ) ដើមខ្នុរចំនួន ១០០ដើម ដើមចេកចំនួន ១០គុម្ព ដើមដំឡូងមីប្រហែលជា ១.៥ហិកតា និងផ្ទះចាំចំការចំនួន ០២ផងដែរ ។ រហូតដល់ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ប្រជាពលរដ្ឋទាំង ១៤គ្រួសារបាននាំគ្នាទៅសាលាឃុំ ដើម្បីឲ្យមេឃុំជួយដោះស្រាយ បន្ទាប់មកខាងអាជ្ញាធរឃុំក៏បានហៅភាគីឈ្មោះ ផែង សូរិយា និងប្រជាពលរដ្ឋទាំង ១៤គ្រួសារមកតទល់ និងយកលិខិតកាន់កាប់ដីធ្លីមកផ្ទៀងផ្ទាត់គ្នា ។ ប៉ុន្តែក្រោយមកខាងអាជ្ញាធរឃុំ ពុំមានដំណោះស្រាយអ្វីមកឲ្យប្រជាពលរដ្ឋជនជាតិពួងទាំង ១៤គ្រួសារឡើយ ។ ហើយពួកខ្លួនក៏បានបន្តដាក់ពាក្យបណ្តឹងទៅសាលាស្រុកអូររាំង និងសាលាខេត្តមណ្ឌលគិរី ប៉ុន្តែនៅតែមិនមានដំណោះស្រាយសមស្របណាមួយទេ ។ រហូតដល់ពួកខ្លួនដាក់ពាក្យបណ្តឹងមកអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរីតែម្តង ។

-ចម្លើយដើមបណ្តឹងឈ្មោះ [redacted] សុខិត បានឆ្លើយថា៖ ដីដែលពួកខ្លួនបានកាន់កាប់ ពុំមានឯកសារបញ្ជាក់ទេ ដោយសំអាងទីមួយ ដាំដំណាំជាក់ស្តែង ទីពីរ រោងចាំចំការលើដី ទីបី មានមន្ទីរដែនដីចុះបង្ហាញផែនទីជាបឋម ដែលមានមេភូមិ ឃុំចូលរួម ហើយដីនេះ មានព្រំប្រទល់ កំណត់ពីផ្លូវជាតិ៣០០ម៉ែត្រ ពីផ្ទាល់ជាតិរួចអស់ហើយជាមួយលោក [redacted] ហាន និងមួយទៀតមានស្នាមមេដៃរបស់ប្រជាពលរដ្ឋបញ្ជាក់ថាជាដីរបស់ពួកខ្លួន ហើយមួយទៀត មានអាជ្ញាធរចុះហត្ថលេខាទទួលស្គាល់ឲ្យពួកខ្លួនទៀត។ រហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ ពួកខ្លួនទាំង ៧៧គ្រួសារបានផ្តិតមេដៃប្រគល់សិទ្ធិឲ្យលោក [redacted] ធ្វើក ជាអ្នកតំណាងឲ្យក្រុមសហគមន៍ និងជាប្រធានគណៈកម្មាធិការសហគមន៍ជនជាតិភាគតិចពួង នៃភូមិពូឆប បានធ្វើពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ជនជាតិភាគតិច ទៅលោកប្រធានមន្ទីររៀបចំដែនដី នគររូបនីយកម្មសំណង់ និងសុរិយោដី ខេត្តមណ្ឌលគិរី តាមរយៈលោកមេឃុំដាក់ដាំ ។ បន្ទាប់មកលោកមេឃុំដាក់ដាំ ក៏បានចេញលិខិតស្តីពីការតែងតាំងគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិចពួងភូមិពូឆប ហើយក៏មានសេចក្តីសម្រេចស្តីពីការតែងតាំងគណៈកម្មាធិការសហគមន៍ជនជាតិភាគពួង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ។ ក្រោយមកក្រសួងមហាផ្ទៃ ក៏បានជម្រាបមកលោក [redacted] ធ្វើក ប្រធានសហគមន៍ជនជាតិដើមភាគតិច ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ។ ហើយក្រសួងដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដី ខេត្តមណ្ឌលគិរី បានធ្វើរបាយការណ៍ស្តីពីលទ្ធផល នៃការកំណត់ព្រំវាស់វែង និងវិនិច្ឆ័យដីសហគមន៍ជនជាតិដើមភាគតិចពួងពូឆប ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ២០១៨ ព្រមទាំងមានប្លង់សុរិយោដី ផងដែរ ។ លុះដល់ឆ្នាំ២០១៧ ឈ្មោះ [redacted] សូរិយា បានយកគ្រឿងចក្រមកឈូស

ឆាយដីខាងលើប្រហែលជា ០១ហិកតា លើកទី១។ ក្រោយមកអំឡុងខែវិច្ឆិកា ឆ្នាំ២០១៨ ឈ្មោះ [redacted]សូរិយា ក៏បានយកគ្រឿងចក្រមកឈូសឆាយបន្តទៀតអស់ទំហំសរុបប្រហែល ១៤ហិកតា នៅលើដីសហគមន៍ជនជាតិភាគតិច ។ បន្ទាប់ពីឃើញសកម្មភាពឈូសឆាយបែបនេះ ពួកខ្លួនទាំង ១៤គ្រួសារបានទៅហាមឃាត់ឈ្មោះ [redacted] សូរិយា មិនឱ្យធ្វើការឈូសឆាយបន្ត ហើយឈ្មោះ [redacted] សូរិយា បានផ្អាកសកម្មភាពឈូសឆាយ បន្ទាប់មកបានឈូសឆាយដំណាំអស់ជាច្រើនមាន៖ ដើមប៉័រចំនួន ២០០ដើម,ដើមកូនកាហ្វេចំនួន ១០៥០ដើម,ដើមស្វាយចំនួន ១០០ដើម (មានអាយុ៥ទៅ៦ឆ្នាំហើយ) ដើមខ្នុរចំនួន ១០០ដើម ដើមចេកចំនួន ១០គុម្ព ដើមដំឡូងមីប្រហែលជា ១.៥ហិកតា និងផ្ទះចាំចំការចំនួន ០២ផងដែរ ។ រហូតដល់ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ប្រជាពលរដ្ឋទាំង ១៤គ្រួសារបាននាំគ្នាទៅសាលាឃុំ ដើម្បីឱ្យមេឃុំជួយដោះស្រាយ បន្ទាប់មកខាងអាជ្ញាធរឃុំក៏បានហៅភាគីឈ្មោះ [redacted] សូរិយា និងប្រជាពលរដ្ឋទាំង ១៤គ្រួសារមកតទល់ និងយកលិខិតកាន់កាប់ដីធ្លីមកផ្ទៀងផ្ទាត់គ្នា ។ ប៉ុន្តែក្រោយមកខាងអាជ្ញាធរឃុំ ពុំមានដំណោះស្រាយអ្វីមកឱ្យប្រជាពលរដ្ឋជនជាតិព្នងទាំង ១៤គ្រួសារឡើយ ។ ហើយពួកខ្លួនក៏បានបន្តដាក់ពាក្យបណ្តឹងទៅសាលាស្រុកអូររាំង និងសាលាខេត្តមណ្ឌលគិរី ប៉ុន្តែនៅតែមិនមានដំណោះស្រាយសមស្របណាមួយទេ ។

-តាមចម្លើយដើមបណ្តឹងឈ្មោះ [redacted]ព្រាង បានឆ្លើយថា៖ ខ្លួន និងប្រជាពលរដ្ឋជនជាតិព្នង គឺបានរស់នៅលើដីដែលមានទីតាំងស្ថិតនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី តាំងពីយូរណាស់មកហើយ ហើយពួកខ្លួនបានដាំដំណាំនៅទីនោះរហូត។ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ស្រាប់តែឈ្មោះ [redacted] សូរិយា ភេទប្រុស និងឈ្មោះ [redacted] ផន បានយកគ្រឿងចក្រទៅឈូសឆាយដីដែលមានទីតាំងខាងលើ ដែលបណ្តាលឱ្យខូចខាតដំណាំពួកខ្លួនជាច្រើន មិនតែប៉ុណ្ណោះនៅក្នុងឆ្នាំ២០១៨ ស្រាប់តែឈ្មោះ [redacted] សូរិយា បញ្ជាឱ្យកម្មករយកគ្រឿងចក្រទៅឈូសឆាយដំណាំពួកខ្លួនបន្ថែមទៀត និងបានរំលោភយកដីពួកខ្លួន ដែលមានទីតាំងខាងលើថែមទៀតផង ហើយខ្លួនពុំបានដឹងថាឈ្មោះ [redacted] សូរិយា ឈូសឆាយដីពួកខ្លួនអស់ប៉ុន្មានហិកតានោះទេ ។

-តាមចម្លើយដើមបណ្តឹងឈ្មោះ [redacted]គារ បានឆ្លើយថា៖ ខ្លួន និងប្រជាពលរដ្ឋជនជាតិព្នង គឺបានរស់នៅលើដីដែលមានទីតាំងស្ថិតនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី តាំងពីយូរណាស់មកហើយ ហើយពួកខ្លួនបានដាំដំណាំនៅទីនោះរហូត ។ លុះដល់ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានចេញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ប្រគល់ដីដែលមានទីតាំងខាងលើមកឱ្យខ្លួន និងប្រជាពលរដ្ឋភូមិពូឆប ដើម្បីបង្កើតជាសហគមន៍ដីជាសមោហភាព សម្រាប់ឱ្យពួកខ្លួនបានអាស្រ័យផលលើដីនោះ ។ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧ ស្រាប់តែឈ្មោះ [redacted] សូរិយា ភេទប្រុស និងឈ្មោះ [redacted] ផន បានយកគ្រឿងចក្រទៅឈូសឆាយដីដែលមានទីតាំងខាងលើ ដែលបណ្តាលឱ្យខូចខាតដំណាំពួកខ្លួនជាច្រើន មិនតែប៉ុណ្ណោះនៅក្នុងឆ្នាំ២០១៨ ស្រាប់តែឈ្មោះ [redacted] សូ

រិយា បញ្ជាឱ្យកម្មករយកគ្រឿងចក្រទៅឈូសឆាយដំណាំពួកខ្លួនបន្ថែមទៀត និងបានរំលោភយកដីពួកខ្លួន ដែលមានទីតាំងខាងលើថែមទៀតផង ហើយឈ្មោះ ផែង សូរិយា ឈូសឆាយដីរបស់ខ្លួន និងដីប្រជាពលរដ្ឋអស់ចំនួនប្រហែល ១៤ ហិកតា ។

-តាមចម្លើយដើមបណ្តឹងឈ្មោះ [redacted] ទីត បានឆ្លើយថា៖ ខ្លួន និងប្រជាពលរដ្ឋជនជាតិព្នង គឺបានរស់នៅលើដីដែលមានទីតាំងស្ថិតនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី តាំងពីយូរណាស់មកហើយ ហើយពួកខ្លួនបានដាំដំណាំនៅទីនោះរហូត ។ លុះដល់ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានចេញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ប្រគល់ដីដែលមានទីតាំងខាងលើមកឱ្យខ្លួន និងប្រជាពលរដ្ឋភូមិពូឆប ដើម្បីបង្កើតជាសហគមន៍ដីជាសមោហភាព សម្រាប់ឱ្យពួកខ្លួនបានអាស្រ័យផលលើដីនោះ ។ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧ ស្រាប់ តែឈ្មោះ [redacted] សូរិយា ភេទប្រុស និងឈ្មោះ [redacted] ផន បានយកគ្រឿងចក្រទៅឈូសឆាយដីដែលមានទីតាំងខាងលើ ដែលបណ្តាលឱ្យខូចខាតដំណាំពួកខ្លួនជាច្រើន មិនតែប៉ុណ្ណោះនៅក្នុងឆ្នាំ២០១៨ ស្រាប់តែឈ្មោះ [redacted] សូរិយា បញ្ជាឱ្យកម្មករយកគ្រឿងចក្រទៅឈូសឆាយដំណាំពួកខ្លួនបន្ថែមទៀត និងបានរំលោភយកដីពួកខ្លួន ដែលមានទីតាំងខាងលើថែមទៀតផង ហើយខ្លួនពុំដឹងឈ្មោះ [redacted] សូរិយា បានឈូសឆាយដីរបស់ពួកខ្លួន អស់ប៉ុន្មាននោះទេ ។

-តាមចម្លើយដើមបណ្តឹងឈ្មោះ [redacted] ហាំ បានឆ្លើយថា៖ ខ្លួន និងប្រជាពលរដ្ឋជនជាតិព្នង គឺបានរស់នៅលើដីដែលមានទីតាំងស្ថិតនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី តាំងពីយូរណាស់មកហើយ ហើយពួកខ្លួនបានដាំដំណាំនៅទីនោះរហូត ។ លុះដល់ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានចេញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ប្រគល់ដីដែលមានទីតាំងខាងលើមកឱ្យខ្លួន និងប្រជាពលរដ្ឋភូមិពូឆប ដើម្បីបង្កើតជាសហគមន៍ដីជាសមោហភាព សម្រាប់ឱ្យពួកខ្លួនបានអាស្រ័យផលលើដីនោះ ។ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧ ស្រាប់តែឈ្មោះ [redacted] សូរិយា ភេទប្រុស និងឈ្មោះ [redacted] ផន បានយកគ្រឿងចក្រទៅឈូសឆាយដីដែលមានទីតាំងខាងលើ ដែលបណ្តាលឱ្យខូចខាតដំណាំពួកខ្លួនជាច្រើន មិនតែប៉ុណ្ណោះនៅក្នុងឆ្នាំ២០១៨ ស្រាប់តែឈ្មោះ [redacted] សូរិយា បញ្ជាឱ្យកម្មករយកគ្រឿងចក្រទៅឈូសឆាយដំណាំពួកខ្លួនបន្ថែមទៀត និងបានរំលោភយកដីពួកខ្លួន ដែលមានទីតាំងខាងលើថែមទៀតផង ហើយឈ្មោះ [redacted] សូរិយា ឈូសឆាយដីរបស់ខ្លួន និងដីប្រជាពលរដ្ឋអស់ចំនួនប្រហែល ១៤ ហិកតា ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានសួរដេញដោលក្នុងសវនាការ ឃើញថាផ្អែកលើអំណានចំលើយដើមបណ្តឹង និងចំលើយដើមបណ្តឹងដែលមានវត្តមានទាំងអស់ ថាពួកគាត់បានដាំដំណាំតាមប្រពៃណី ហើយចម្លើយនេះស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សូរិយា បានយកគ្រឿងចក្រចូលឈូសឆាយ



Scanned with CamScanner

ដំណាំរបស់ប្រជាពលរដ្ឋជនជាតិដើមភាគតិច ដែលមានទីតាំងស្ថិតនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ប្រាកដមែន ។ ហេតុនេះតំណាងអយ្យការប្ដឹងចោទប្រកាន់ជនជាប់ពីបទ: **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ។

-មេធាវីជនការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋាន៖ ក្រោយពីបានស្ដាប់ការសួរដេញដោល និង ក្រោយពីបានស្ដាប់ការសន្និដ្ឋានរបស់តំណាងអយ្យការ៖ ឃើញថា កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧ កូនក្ដីខ្លួន ពិតជាឈ្នួសឆាយដីនៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូរាំង ខេត្តមណ្ឌលគិរី ពិតប្រាកដមែន។ ប៉ុន្តែការឈ្នួសឆាយនេះ គឺកូនក្ដីខ្លួន គ្រាន់តែស៊ីឈ្នួស ឈ្នួសឆាយដីចំការ តាមការជួលរបស់ឈ្មោះ ជា តែប៉ុណ្ណោះ ។ ហើយមុនពេលឈ្នួសឆាយ គឺឈ្មោះ ជា បានបង្ហាញឯកសារពាក់ព័ន្ធនិងទីតាំងដីខាងលើ ដូចមានក្នុងពាក្យ សុំបញ្ចូលភស្តុតាង ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ក្នុងសំណុំរឿងស្រាប់ មកអោយកូនក្ដីខ្លួនមើល ហើយម្យ៉ាងទៀត កូនក្ដីខ្លួនធ្លាប់ធ្វើជាសាក្សី ក្នុងការទិញលក់ដីផ្លែងទំនាស់នេះ រវាងឈ្មោះ [redacted] ចាន់លី និងឈ្មោះ [redacted] សុខណា ដូចមានក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៦ ។

ចំពោះការលើកឡើងរបស់មេធាវី ការពារសិទ្ធិអោយដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានអះអាងថា កូនក្ដីខ្លួនមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងឈ្មោះ ជា នោះ គឺជារឿងមិនពិតនោះទេ ហើយសួររកឯកសារប្រគល់សិទ្ធិ ឬលិខិតផ្ទេរសិទ្ធិពីម្ចាស់ដីដើមនោះ គឺកូនក្ដីខ្លួន ពុំយល់ដឹងអំពីផ្លូវច្បាប់ទេ ។ នៅពេលប្រជាពលរដ្ឋ ទៅហាមឃាត់កូនក្ដីខ្លួនមិនអោយមានការឈ្នួសឆាយ កូនក្ដីខ្លួន បានចូលរួមដោះស្រាយនៅសាលាឃុំ តែពុំមានដំណោះស្រាយ ទើបកូនក្ដីខ្លួនឈ្នួសឆាយបន្ត ហើយការឈ្នួសឆាយនេះ គឺកូនក្ដីខ្លួន គ្រាន់តែបំពេញតួនាទី ជាអ្នកស៊ីឈ្នួលឈ្នួសឆាយដីតែប៉ុណ្ណោះ។

ទីតាំងដីដែលកូនក្ដីខ្លួនបានស៊ីឈ្នួលឈ្នួសឆាយសព្វថ្ងៃនេះ បើតាមការអះអាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សុផាត គឺលែងជាដីសហគមន៍ ឬដីចំការវិលជុំ របស់ជនជាតិដើមភាគតិចទៀតហើយ នេះបញ្ជាក់អោយឃើញថា ទីតាំងដីដែលកូនក្ដីខ្លួន បានឈ្នួសឆាយ គឺពិតជាដីរបស់ឯកជន ដែលជួលកូនក្ដីខ្លួនទៅឈ្នួសឆាយពិតមែន ។

ចំពោះឯកសារដែលដើមបណ្ដឹង បានដាក់អោយតុលាការពិនិត្យ និងការអះអាងរបស់ដើមបណ្ដឹង ឃើញថាមិនទាន់មានភាពត្រឹមត្រូវ ច្បាស់លាស់ និងជាក់លាក់នៅឡើយ ហេតុនេះ ក្នុងនាមខ្លួន ជាមេធាវីការពារក្ដី អោយជនជាប់ចោទ ស្នើសុំអោយចៅក្រមជំនុំជម្រះ មេត្តាពិចារណា និងសម្រេច លើកលែងចោទអោយកូនក្ដីខ្លួន ពីបទ ធ្វើអោយខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិពូឆប ឃុំដាក់ដាំ ស្រុក អូរាំង ខេត្តមណ្ឌលគិរី តាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

-មេធាវីជនការពារសិទ្ធិឱ្យសហដើមបណ្ដឹងធ្វើសេចក្ដីសន្និដ្ឋាន៖ ដោយផ្អែកតាមដីកាសន្និដ្ឋានស្ថាពរ និង ដីកាដំណោះស្រាយ សហគមន៍ពួកយើងបានរស់នៅលើដីច្បាស់លាស់ ហើយបានរៀបចំដីរបស់សហគមន៍ត្រឹមត្រូវ ដែលមានពាក្យស្នើសុំស្របតាមច្បាប់ ដែលមានក្រសួងពាក់ព័ន្ធទទួលស្គាល់ ។ ហើយដីរបស់សហគមន៍របស់ជន



Scanned with CamScanner

ជាតិភាគតិច មានដាំដំណាំ ហើយត្រូវលោក [redacted] សូរិយា ឈូសឆាយបំផ្លិចបំផ្លាញអស់ ហេតុដូចនេះសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សូរិយា សំណូមពរសុំឱ្យតុលាការរកយុត្តិធម៌ឱ្យខ្លួនផង ព្រោះខ្លួនគ្រាន់តែជាអ្នកស៊ីឈ្នួលឈូសឆាយដីឱ្យគេតែប៉ុណ្ណោះ លើកលែងចោទប្រកាន់ដល់ខ្លួន ព្រោះថាដីនេះ មានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវពីឈ្មោះ [redacted] ស្រីថាន, [redacted] ចាន់លី មិនត្រឹមតែប៉ុណ្ណោះ ខ្លួនក៏ធ្វើជាសាក្សីនៅក្នុងការទិញលក់ លើលិខិតផ្ទេរសិទ្ធិនេះដែរ ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹង
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីសិទ្ធិឱ្យសហដើមបណ្តឹង
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យលើភស្តុតាង
- ក្រោយពីពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## **<u>សំអាងហេតុ</u>**

ពិតជាមានអង្គហេតុកើតឡើងកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧ និងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៨ ឈ្មោះ [redacted] សូរិយា បានយកគ្រឿងចក្រចូលឈូសឆាយដីមួយកន្លែងដែលមានទីតាំងស្ថិតនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី បណ្តាលឱ្យខូចខាតដំណាំមួយចំនួនមានដូចជា៖ ដើមស្វាយ ចេក ខ្នុរ ម្នាស់ ប័រ កាហ្វេ និង ផ្ទះចាំចំការ ពិតប្រាកដមែន ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សូរិយា បានឆ្លើយថា៖ នៅឆ្នាំ២០១៧ ខ្លួនបានស៊ីឈ្នួលឈូសឆាយដីឱ្យឈ្មោះ ជា ពិតមែន ដោយឈ្មោះ ជា បានបង្ហាញឯកសារលក់-ទិញ ពីប្រជាពលរដ្ឋដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី របស់ឈ្មោះ ហួត ចាន់លី ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៦, លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី របស់ឈ្មោះ [redacted] ស្រីថាន ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៦ និងគំនូសបង្ហាញទ្រង់ទ្រាយដីវាស់ដោយ GPS India Thai Lang60 ចុះហត្ថលេខាទទួលស្គាល់ឱ្យអាជ្ញាធរមានសមត្ថកិច្ចតាមលំដាប់ ដែលមានទីតាំងនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ទំហំប្រហែល ១០ហិកតា ដោយរាប់អានគ្នា ខ្លួនក៏យកថ្លៃឈ្នួល ៥.០០០ (ប្រាំពាន់) ដុល្លាអាមេរិច ។ បន្ទាប់មកក៏បានយកគ្រឿងចក្រចូលឈូសឆាយដី ទៅតាមការសន្យាគ្នាតាមចំណុចប្លង់កាន់កាប់ដីនោះ ខ្លួនឃើញមានដំណាំ ហើយម្ចាស់ដីក៏ប្រាប់ថាឱ្យឈូសសំអាតទាំងអស់ទៅ ខ្លួនជាអ្នកស៊ីឈ្នួល ខ្លួនក៏ឈូស តាមម្ចាស់គេទៅ។ នេះជាចេតនាដែលធ្វើឱ្យខូចខាតដំណាំមានដូចជាដើមប័រ ចំនួន ១០ដើម ម្នាស់ និងដំឡូងមី របស់ប្រជាពលរដ្ឋពិតប្រាកដមែន ដោយហេតុថា ក្នុងការស៊ីឈ្នួសឈូសឆាយដីនេះ ត្រូវបានម្ចាស់ដំណាំមកហាមឃាត់កុំឱ្យឈូសឆាយចំនួនពីរដង តែឈ្មោះ [redacted] សូរិយា នៅតែឈូសឆាយបំផ្លិចបំផ្លាញដំណាំរហូតទាល់តែខ្ទិចអស់ ដូចនេះឈ្មោះ [redacted] សូរិយា ត្រូវតែទទួលខុសត្រូវនៅទង្វើរបស់ខ្លួន



Scanned with CamScanner

ស្របតាមមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ ។ ដែលអំពើរបស់ឈ្មោះ [redacted] សូរិយា ចូលជាតុផ្សំនៃបទល្មើស ពីបទ៖ ធ្វើឱ្យខូចខាតដោយចេតនា តាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

- តាមចម្លើយដើមបណ្តឹងឈ្មោះ [redacted] តាយ, [redacted] សុផាត, [redacted] សុខិត, [redacted] ព្រាង, [redacted] គា, [redacted] ហាំ បានឆ្លើយប្រហាក់ប្រហែលគ្នាថា៖ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ឈ្មោះ [redacted] សូរិយា បានយកគ្រឿងចក្រទៅឈូសឆាយដីក្នុងដីសហគមន៍ជនជាតិដើមភាគតិច ដែលជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋជនជាតិភាគតិច ដែលបណ្តាលឱ្យខូចខាតដំណាំពួកខ្លួនជាច្រើន ដូចជាដើមប៉័រ ចំនួន ១០ដើម ម្នាស់ និងដំឡូងមី ពិតប្រាកដមែន ដូចនេះអំពើរបស់ឈ្មោះ [redacted] សូរិយា ចូលជាតុផ្សំនៃបទល្មើស ពីបទ៖ ធ្វើឱ្យខូចខាតដោយចេតនា តាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។ មួយវិញទៀតសហដើមបណ្តឹងថាឈ្មោះ [redacted] សូរិយា ឈូសឆាយរំលោភយកនោះជាដីសហគមន៍ជនជាតិដើមភាគតិច ដោយដំណាំលើដីជាក់ស្តែង និងតាមការស្នើសុំនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ ពួកខ្លួនទាំង ៧៧គ្រួសារ បានផ្តិតមេដៃប្រគល់សិទ្ធិឱ្យលោក [redacted] ធ្វើក ជាអ្នកតំណាងឱ្យក្រុមសហគមន៍ និងជាប្រធានគណៈកម្មាធិការសហគមន៍ជនជាតិភាគតិចក្នុងនៃភូមិពូឆប បានធ្វើពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ជនជាតិភាគតិច ទៅលោកប្រធានមន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តមណ្ឌលគិរី តាមរយៈលោកមេឃុំដាក់ដាំ។ បន្ទាប់មកលោកមេឃុំដាក់ដាំ ក៏បានចេញលិខិតស្តីពីការតែងតាំងគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិចក្នុងភូមិពូឆប ហើយក៏មានសេចក្តីសម្រេចស្តីពីការតែងតាំងគណៈកម្មាធិការសហគមន៍ជនជាតិភាគក្នុង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥។ ក្រោយមកក្រសួងមហាផ្ទៃ ក៏បានជម្រាបមកលោក [redacted] ធ្វើក ប្រធានសហគមន៍ជនជាតិដើមភាគតិច ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ។ ហើយក្រសួងដែនដីនគររូបនីយកម្មសំណង់ និងសុរិយោដី ខេត្តមណ្ឌលគិរី បានធ្វើរបាយការណ៍ស្តីពីលទ្ធផល នៃការកំណត់ព្រំវាស់វែង និងវិនិច្ឆ័យដីសហគមន៍ជនជាតិដើមភាគតិចក្នុងពូឆប ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ព្រមទាំងមានប្លង់សុរិយោដី ផងដែរ ។ និងនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានចេញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ប្រគល់ដីដែលមានទីតាំងខាងលើមកឱ្យខ្លួន និងប្រជាពលរដ្ឋភូមិពូឆប ដើម្បីបង្កើតជាសហគមន៍ដីជាសមោហភាព សម្រាប់ឱ្យពួកខ្លួនបានអាស្រ័យផលលើដីនោះ ។ ប៉ុន្តែតាមការអះអាងរបស់ឈ្មោះ [redacted] សូរិយា ថាខ្លួនជាអ្នកស៊ីឈ្នួលឈូសឆាយដីឱ្យឈ្មោះ ជា ពិតមែន ដោយឈ្មោះ ជា បានបង្ហាញឯកសារលក់-ទិញ ពីប្រជាពលរដ្ឋដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី របស់ឈ្មោះ [redacted] ចាន់លី ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៦, លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី របស់ឈ្មោះ [redacted] ស្រីថាន ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៦ និងគំនូសបង្ហាញទ្រង់ទ្រាយដីវាស់ដោយ GPS India Thai Lang60 ចុះហត្ថលេខាទទួលស្គាល់ឱ្យអាជ្ញាធរមានសមត្ថកិច្ចតាមលំដាប់ ដែលមានទីតាំងនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ទំហំប្រហែល ១០ហិកតា ដោយរាប់អានគ្នា ខ្លួនក៏យកថ្លៃឈ្នួល ៥.០០០ (ប្រាំពាន់) ដុល្លាអាមេរិច ។ ហើយដីនេះពុំមានជាកម្មសិទ្ធិរបស់ខ្លួនទេ ។ បន្ទាប់មកខ្លួនក៏បានយកគ្រឿងចក្រចូលឈូសឆាយដី ទៅតាមការសន្យាគ្នាតាមចំណុចប្លង់កាន់កាប់ដីនោះ ខ្លួនឃើញមានដំណាំ ហើយម្ចាស់ដីក៏ប្រាប់ថាឱ្យឈូសសំអាតទាំងអស់ទៅ ខ្លួនជាអ្នកស៊ីឈ្នួល ខ្លួនក៏ឈូស តាមម្ចាស់គេតែម្តង។ មួយវិញទៀតខ្លួនដឹងដីនេះច្បាស់បានប៊ានឈូសឆាយ ព្រោះខ្លួនបានធ្វើជាសាក្សីក្នុងការទិញលក់ដីរបស់ឈ្មោះ ហួត ចាន់លី និងឈ្មោះ [redacted] ស្រីថាន ។ ពេលខ្លួនឈូសឆាយដីបាន



Scanned with CamScanner

ប្រហែលមួយសប្តាហ៍ក្រោយមក ស្រាប់តែមានប្រជាពលរដ្ឋជនជាតិព្នងមកហាមឃាត់ ហើយខ្លួនក៏បានបង្ហាញឯកសារម្ចាស់ដី និងបានផ្អាកការឈូសឆាយសិន និងបាននាំគ្នាទៅដោះស្រាយនៅសាលាឃុំដាក់ដាំ រឿងដំណាំ តែជនជាតិគាត់ទាមទារតែដី ខ្លួនពុំមែនជាម្ចាស់ដីទេ។ នេះសបញ្ជាក់ឱ្យឃើញថា ការអះអាងរបស់ដើមបណ្តឹង ថាដីដែលឈ្មោះ [redacted] សូរិយា ឈូសឆាយជាដីរបស់សហគមន៍ជនជាតិដើមភាគតិចនៅភូមិពូឆប នោះគឺពុំមែនជាដីរបស់សហគមន៍ជនជាតិដើមភាគតិចនៅភូមិពូឆប ព្រោះថាទាក់ទង់និង អនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩,របាយការណ៍ស្តីពីលទ្ធផល នៃការកំណត់ព្រំវាស់វែង និងវិនិច្ឆ័យដីសហគមន៍ជនជាតិដើមភាគតិចព្នងពូឆប ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ និងលិខិតលេខ ២៣៦ សជណ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ គឺជានីតិវិធីនៃការស្នើសុំចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិចព្នងពូឆប តែប៉ុណ្ណោះ ដែលពុំទាន់មានឯកសារចេញដោយអាជ្ញាធរមានសមត្ថកិច្ចបញ្ជាក់ថា ដីដែលបានស្នើសុំទៅហើយនោះ ជាដីរបស់សហគមន៍ជនជាតិដើមភាគតិចព្នងពូឆប ពិតប្រាកដនោះទេ ដូចនេះតុលាការពុំលើកមកពិចារណាទេ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានសួរដេញដោលក្នុងសវនាការ ឃើញថាផ្អែកលើអំណានចំលើយដើមបណ្តឹង និងចំលើយដើមបណ្តឹងដែលមានវត្តមានទាំងអស់ ថាថាពួកគាត់បានដំណាំតាមប្រពៃណី ហើយចម្លើយនេះស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សូរិយា បានយកគ្រឿងចក្រចូលឈូសឆាយដំណាំរបស់ប្រជាពលរដ្ឋជនជាតិដើមភាគតិច ដែលមានទីតាំងស្ថិតនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ប្រាកដមែន ។ ហេតុនេះតំណាងអយ្យការប្តឹងចោទប្រកាន់ជនជាប់ពីបទ: **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ។

-មេធាវីជនការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន៖ ក្រោយពីបានស្តាប់ការសួរដេញដោល និងក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់តំណាងអយ្យការ៖ ឃើញថា កាលពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៧ កូនក្តីខ្លួនពិតជាឈូសឆាយដីនៅចំណុចភូមិពូឆប ឃុំដាក់ដាំ ស្រុកអូរាំង ខេត្តមណ្ឌលគិរី ពិតប្រាកដមែន។ ប៉ុន្តែការឈូសឆាយនេះគឺកូនក្តីខ្លួន គ្រាន់តែស៊ីឈ្នួស ឈូសឆាយដីចំការ តាមការជួលរបស់ឈ្មោះ ជា តែប៉ុណ្ណោះ ។ ហើយមុនពេលឈូសឆាយ គឺឈ្មោះ ជា បានបង្ហាញឯកសារពាក់ព័ន្ធនិងទីតាំងដីខាងលើ ដូចមានក្នុងពាក្យ សុំបញ្ចូលភស្តុតាង ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ក្នុងសំណុំរឿងស្រាប់ មកអោយកូនក្តីខ្លួនមើល ហើយម្យ៉ាងទៀត កូនក្តីខ្លួនធ្លាប់ធ្វើជាសាក្សី ក្នុងការទិញលក់ដី កន្លែងទំនាស់នេះ រវាងឈ្មោះ [redacted]ចាន់លី, [redacted] ស្រីថាន និងឈ្មោះ [redacted] សុខណា ដូចមានក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ៤៤៩/១៦ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៦ និងលិខិតលេខ ៤៤៧/១៦ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៦ និងគំនូសបង្ហាញទ្រង់ទ្រាយដីវាស់ដោយ GPS India Thai Lang60 ចុះហត្ថលេខាទទួលស្គាល់ដោយមេឃុំដាក់ដាំ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១១ ។ ក្នុងនាមខ្លួន ជាមេធាវីការពារក្តីអោយជនជាប់ចោទ ខ្លួនស្នើសុំទៅក្រុមជំនុំជម្រះមេត្តាពិចារណា និងសម្រេចលើកលែងចោទអោយកូនក្តីខ្លួន ពីបទ ធ្វើអោយខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូរាំង ខេត្តមណ្ឌលគិរី តាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។ តុលាការពុំឯកភាពតាមការស្នើ

សុំនោះទេ ដោយហេតុថា ឈ្មោះ [redacted] សូរិយា ពិតជាបានសារភាពឈូសឆាយបំផ្លិចបផ្លាញធ្វើឱ្យខូចខាតដំណាំរបស់ប្រជាពលរដ្ឋ ពិតប្រាកដមែន ជាចេតនាទុច្ចរិត ដែលច្បាប់បានបញ្ញត្តិ ជាបទល្មើល ជាបទ៖ធ្វើឱ្យខូចខាតដោយចេតនា តាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

-មេធាវីជនការពារសិទ្ធិឱ្យសហដើមបណ្តឹងធ្វើសេចក្តីសន្និដ្ឋាន៖ ដោយផ្អែកតាមដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយ សហគមន៍ពួកយើងបានរស់នៅលើដីច្បាស់លាស់ ហើយបានរៀបចំដីរបស់សហគមន៍ត្រឹមត្រូវ ដែលមានពាក្យស្នើសុំស្របតាមច្បាប់ ដែលមានក្រសួងពាក់ព័ន្ធទទួលស្គាល់ ។ ហើយដីរបស់សហគមន៍របស់ជនជាតិភាគតិច មានដាំដំណាំ ហើយត្រូវលោក [redacted] សូរិយា ឈូសឆាយបំផ្លិចបំផ្លាញអស់ ហេតុដូចនេះសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

-ជនជាប់ចោទជានីតិជនមានសញ្ញាណបញ្ជាក់ថា មិនកើតវិបល្លាសស្មារតីទេ ដូច្នេះជននេះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌលើអំពើរបស់ខ្លួន ដែលបានប្រព្រឹត្តបទល្មើស តាមមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ ។

-មានពិរុទ្ធភាពនិងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] សូរិយា ពីបទ: **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ [redacted] សូរិយា ទើបតែប្រព្រឹត្តបទល្មើសលើកដំបូង ដោយហេតុថា ខ្លួនជាអ្នកស៊ីឈ្នួលស្របច្បាប់ ព្រោះម្ចាស់ដីមានឯកសារត្រឹមត្រូវ ហើយបានចូលរួមដោះស្រាយរឿង ការខូចខាតដំណាំដែរ តែសហដើមបណ្តឹងទាមទារតែដី គប្បីតុលាការពិចារណា។

-ក្រោយពិតនិត្យទៅលើអង្គហេតុ អង្គច្បាប់ និងភស្តុតាងនៅក្នុងសំណុំរឿង ឃើញថា ពិតជាមានអំពើធ្វើឱ្យខូចខាតដោយចេត ដែលប្រព្រឹតដោយឈ្មោះ[redacted]សូរិយា ពិតមែន តាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។ ចំណែកឯភស្តុតាងដែលសហដើមបណ្តឹងដាក់ចូល មានដូចជា អនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០០៩, របាយការណ៍ស្តីពីលទ្ធផលនៃការកំណត់ព្រំវាស់វែង និងវិនិច្ឆ័យដីសហគមន៍ជនជាតិដើមភាគតិចពួងពូឆប ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ និងលិខិតលេខ ២៣៦ សជណ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ និងបទបញ្ជាផ្ទៃក្នុង ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៦ និង លក្ខន្តិកៈ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៥ គឺជានីតិវិធីនៃការស្នើសុំចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិចពួងពូឆបទេ ពុំមានឯកសារចេញដោយអាជ្ញាធរមានសមត្ថកិច្ចបញ្ជាក់ថា ដីដែលបានស្នើសុំទៅហើយនោះ ជាដីរបស់សហគមន៍ជនជាតិដើមភាគតិចពួងពូឆប ពិតប្រាកដនោះទេ គប្បីតុលាការពិចារណា។

## <u>ហេតុដូច្នេះទិនិច្ឆ័យសេចក្តី</u>

១/ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted]សូរិយា ភេទប្រុស អាយុ ៣៤ឆ្នាំ ដាក់ពន្ធនាគារចំនួន០១(មួយ)ឆ្នាំ តែទោសនេះព្យួរទាំងមូល ពីបទ: **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិពូឆប ឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី

កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១០,១០៨ នៃក្រមព្រហ្មទណ្ឌ ។

២/បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] សូរិយា ភេទប្រុស អាយុ ៣៤ឆ្នាំ សងសំណងការខូចខាងទៅសហដើមបណ្តឹងចំនួន៨០០០០០០(ប្រាំបីលាន)រៀល គិតចាប់ថ្ងៃសាលក្រមនេះចូលជាស្ថាពរ ។

២/សាលក្រមនេះជំនុំជំរះនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០២២ និងប្រកាសជាសាធារណះនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០២២ ចំពោះមុខមេធាវីសហដើមបណ្តឹង និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងចំពោះមុខដើមបណ្តឹង និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សូរិយា តែចាត់ទុកចំពោះមុខ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១១រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥
មណ្ឌលគិរី,ថ្ងៃទី២៧ ខែ មេសា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**

[redacted]